អង្គភាពសវនកម្មផ្ទៃក្នុង
INTERNAL AUDIT UNIT

# អត្ថបទប្រចាំខែ

លេខ ៨ ចេញផ្សាយ ខែសីហា ឆ្នាំ២០២២

## ផលប្រយោជន៍នៃអនុលោមភាព

អនុលោមភាព មានសារៈសំខាន់ណាស់ក្នុងការអនុវត្តកាតព្វកិច្ចតាមផ្នែកឬតាមជំនាញរបស់ស្ថាប័ន ឬអង្គភាពនីមួយៗ។ ដូចនេះ គ្រប់អង្គភាព ស្ថាប័ន និងគ្រប់វិស័យទាំងអស់ ចាំបាច់ត្រូវគោរព និងអនុលោមតាមច្បាប់ ឬបទប្បញ្ញត្តិ ដើម្បីបំពេញតួនាទី ភារកិច្ចក្នុងវិស័យរៀងៗខ្លួនមិនថាទាំងវិស័យឯកជន ឬវិស័យសាធារណៈ។ ជាមួយគ្នានេះ បុគ្គលិក ឬមន្ត្រីដែលបម្រើការងារនៅវិស័យសាធារណៈ ក៏ចាំបាច់ត្រូវអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលគ្រប់គ្រងលើប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួន ដោយរាប់បញ្ចូលទាំងវិធាន និងនីតិវិធីដែលបង្កើតដោយស្ថាប័នរបស់ខ្លួនផ្ទាល់ ដូចជាបទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌ វិធាននីតិវិធីគ្រប់គ្រងបុគ្គល និងរដ្ឋបាលនានា។ ទន្ទឹមនឹងនេះ ការគ្រប់គ្រង ឬអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងវិធានបានត្រឹមត្រូវនិងពេញលេញ អាចជួយលើកកម្ពស់ការគ្រប់គ្រងស្ថាប័នបានល្អផងដែរ។

### និយមន័យ

តាមការសិក្សាស្រាវជ្រាវពាក្យ អនុលោមភាព ត្រូវបានផ្តល់និយមន័យផ្សេងៗគ្នា អាស្រ័យលើស្ថាប័នដូចខាងក្រោម÷

១. អនុលោមភាពសំដៅដល់សកម្មភាពដែលប្រកាន់ខ្ជាប់តាមច្បាប់បទប្បញ្ញត្តិគោលនយោបាយស្តង់ដារបស់ស្ថាប័នគោលការណ៍អភិបាលកិច្ច និងស្តង់ដាសីលធម៌។

២. អនុលោមភាពសំដៅដល់ការអនុលោមតាមការតម្រូវរបស់ បទប្បញ្ញត្តិ និងនីតិវិធីផ្ទៃក្នុងដែលស្របតាមសកម្មភាពធុរកិច្ច ឬកិច្ច ដំណើរការរបស់ស្ថាប័ន។

### អត្ថប្រយោជន៍

- ជួយពង្រឹងដល់ការអនុវត្តការងារប្រចាំថ្ងៃរបស់ស្ថាប័ន ដូចជាការគ្រប់គ្រងហានិភ័យបានកាន់តែល្អស្របតាមការអនុវត្តអនុលោមភាពដែលមានប្រសិទ្ធភាពខ្ពស់និងការស្គាល់ពីតម្រូវការនៃការប្រយ័ត្នប្រយែង ដោយហេតុថាគ្រប់ដំណាក់កាលនៃការត្រួតពិនិត្យ និងវាយតម្លៃតែងមានការរាយការណ៍បន្ទាន់ដល់បុគ្គលទទួលបន្ទុកអនុវត្តការងារ និងថ្នាក់គ្រប់គ្រង ដើម្បីរៀបចំយន្តការ នីតិវិធីនៃការកែតម្រូវបន្ទាន់លើបញ្ហា ឬបុគ្គលដែលមិនអនុលោម។
- គ្រប់គ្រងទ្រព្យសកម្មអាជីវកម្ម ដោយកាត់បន្ថយនូវការភាន់ច្រឡំរអាក់រអួលដែលមិនបានដឹងមុនឬការអនុវត្តមិនសមស្របណាមួយតាមរយៈការការពាបន្ទាន់ ការកែតម្រូវ និងការកាត់បន្ថយថ្លៃចំណាយប្រតិបត្តិការ និងហានិភ័យហិរញ្ញវត្ថុ។
- ការមិនអនុលោមរបស់ស្ថាប័នអាចនឹងត្រូវទទួលរងនូវទណ្ឌកម្ម ឬការពិន័យតាមច្បាប់ឬបទប្បញ្ញត្តិជាធរមានអាចនឹងបណ្តាលឱ្យទទួលនូវការដាក់បន្ទុកលើវិន័យ ដែលអាចរំខានដល់កេរ្តិ៍ឈ្មោះស្ថាប័ន ដោយហេតុថាទណ្ឌកម្មមួយចំនួនអាចត្រូវប្រឈមនឹងការបង្ហាញ ជាសាធារណៈដល់សាធារណជន ឬភាគីពាក់ព័ន្ធ។
- ការគ្រប់គ្រងអនុលោមភាព តម្រូវឱ្យស្ថាប័នរៀបចំបញ្ជីត្រួតពិនិត្យ លើការរៀបចំប្រព្រឹត្តទៅជាប្រចាំតាមដានប្រតិបត្តិការសំខាន់ និងត្រួតពិនិត្យនូវកាតព្វកិច្ចរបស់ស្ថាប័នលើកិច្ចសន្យានានាជាប្រចាំ ដែលការណ៍នេះអនុលោមភាពជួយលុបបំបាត់នូវហានិភ័យវិវាទ និងការពិន័យលើការមិនអនុវត្តតាមបានយ៉ាងមានប្រសិទ្ធភាពខ្ពស់ និងបង្កើនទំនុកចិត្តសាធារណជនតាមរយៈសុចរិតភាពរបស់ស្ថាប័ន ដែលកាន់តែរឹតចំណងទំនាក់ទំនងជាមួយដៃគូ ឬភាគីកិច្ចសន្យាកាន់តែរឹងមាំ។

**អត្ថបទ÷** លោក **រតនា បញ្ញាសម្បត្តិ**

***ឯកសារយោង÷***

*១-សៀវភៅឧត្តមានុវត្តន៍នៃការគ្រប់គ្រងអនុលោមភាពរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ. ស. ហ.***

អត្ថបទអប់រំខ្លីៗស្តីពីសវនកម្មត្រូវបានរៀបរៀងដោយមន្ត្រីរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ. ស. ហ.
ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

ស្កេនទាញយកអត្ថបទស្តីពីសវនកម្មផ្សេងទៀត